ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា

លេខ ...................... .រ.ស.

# សូមជម្រាបជូន

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**តាមរយៈ** : សម្តេចអគ្គមហាពញាចក្រីកិត្តិព្រឹទ្ធបណ្ឌិត ហេង សំរិន ប្រធានរដ្ឋសភា

**កម្មវត្ថុ** : សំណើយកថ្ងៃទី០៤ ខែមិថុនា ជាទិវាកាន់ទុក្ខរបស់ខ្មែរគ្រប់រូប ។

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំជាអ្នកតំណាងរាស្ត្រខ្មែរមានកិត្តិយស សូមជម្រាប **សម្តេច នាយករដ្ឋមន្ត្រី** មេត្តាជ្រាបថា កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩ បារាំងបានកាត់ទឹកដីរបស់ខ្មែរដ៏ធំល្វឹងល្វើយមានផ្ទៃដី ៦៨,៩៦៥គីឡូម៉ែត្រក្រឡា មាន ២១ខេត្ត និងមួយរាជធានី ***គឺរាជធានីព្រៃនគរ*** មាន ១៤,៧៧៨ភូមិ មាន ១,៣៦៨ឃុំ មាន ១៧១ស្រុក មានប្រជាពលរដ្ឋខ្មែរប្រមាណ១២,៥៤៧,២៥០នាក់ មានវត្តព្រះពុទ្ធសាសនាខ្មែរជាង ៥៦៧វត្ត មានព្រះសង្ឃ ព្រះពុទ្ធសាសនាខ្មែរជាង ១ម៉ឺនអង្គ ឱ្យទៅវៀតណាមធ្វើអាណានិគមបន្តរហូតមកដល់សព្វថ្ងៃនេះ ។ ការបាត់បង់ទឹកដីរបស់ខ្មែរដ៏ធំធេងនោះ បានធ្វើឱ្យប្រជាពលរដ្ឋខ្មែរនៅដែនដីកម្ពុជាក្រោមរងនូវការឈឺចាប់គ្រប់ពេលវេលា ហើយពួកគាត់បានធ្វើការតស៊ូពីជំនាន់មួយ ទៅជំនាន់មួយ ដោយសារតែចង់រក្សាការពារ ជាតិសាសន៍ ប្រពៃណី ទំនៀមទំលាប់ វប្បធម៌ អក្សរសាស្ត្រ និងពង្សាវតាររបស់ខ្មែរឱ្យបានស្ថិតស្ថេរគង់វង្ស ។ នៅក្នុងតំណាក់កាលតស៊ូនោះ មានប្រជាពលរដ្ឋខ្មែរ រាប់ពាន់ រាប់ម៉ឺន រាប់សែននាក់ ត្រូវបានធ្វើទារុណកម្មយ៉ាងឃោរឃៅ រហូតដល់បាត់បង់ជីវិត ដោយសារការបង្ក្រាបពីសំណាក់អាជ្ញាធរវៀតណាម ។ ថ្ងៃទី០៤ ខែមិថុនា ជារៀងរាល់ឆ្នាំ បងប្អូនជនរួមឈាមខ្មែរកម្ពុជាក្រោមនៅជុំវិញពិភពលោក តែងបាន ប្រារព្ធទិវាបាត់បង់ទឹកដី គឺជាការកាន់ទុក្ខរបស់ខ្មែរកម្ពុជាក្រោម ។

ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះជាតិ យើងខ្ញុំជាអ្នកតំណាងរាស្ត្រគណបក្ស សម រង្ស៊ី ស្នើសុំឱ្យរាជរដ្ឋាភិបាលកម្ពុជាកំណត់យកថ្ងៃទី០៤ ខែមិថុនា ជាទិវាកាន់ទុក្ខនៃការបាត់បង់ទឹកដីកម្ពុជាក្រោម ជារបស់ខ្មែរយើងទាំងអស់គ្នា ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសម្តេចនាយករដ្ឋមន្ត្រី មេត្តាពិនិត្យ និងសម្រេចតាមសំណើដោយសេចក្តីអនុគ្រោះ ដើម្បីជាឧត្តមប្រយោជន៍នៃមាតុភូមិរបស់ខ្មែរយើង ។

សូមសម្តេច ទទួលនូវការស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ អំពីយើងខ្ញុំ ។

*រាជធានីភ្នំពេញ*, ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១១

បានឃើញ និងបញ្ជូនមក

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

“ដើម្បីមុខការ” ។

ភ្នំពេញ, ថ្ងៃទី.........ខែ......... ឆ្នាំ២០១១

**ប្រធានរដ្ឋសភា**

**<u>ចម្លងជូន</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-គណៈកម្មាធិការរៀបចំបុណ្យជាតិ-អន្តរជាតិ
-សារពត៌មានជាតិ-អន្តរជាតិ
-ឯកសារ & កាលប្បវត្តិ